

គោលនយោបាយសង្ខេប

# យុវជនកម្ពុជា និង វិស័យស្រាវជ្រាវ

## បញ្ហាប្រឈម ឱកាស និង អនុសាសន៍

ហេង គីមគង់

Australian Aid

ពន្លក ចំណេះ

The Asia Foundation

# យុវជនកម្ពុជា និង វិស័យស្រាវជ្រាវ

## បញ្ហាប្រឈម ឱកាស និង អនុសាសន៍

គោលនយោបាយសង្ខេប

## សេចក្តីផ្តើម

របាយការណ៍ស្រាវជ្រាវនេះគឺជារបាយការណ៍មួយនៃរបាយការណ៍ស្រាវជ្រាវជាច្រើនទៀតដែលត្រូវបានគាំទ្រដោយ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់ អង្គការមូលនិធិអាស៊ី។ កម្មវិធីនេះមានគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការស្រាវជ្រាវប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា។

នៅក្នុងរបាយការណ៍នេះ សំណួរចំនួនបីត្រូវបានលើកឡើង៖

1. តើឱកាស និងបញ្ហាប្រឈមអ្វីខ្លះដែលយុវជនកម្ពុជាជួបប្រទះក្នុងការចូលរួមនៅក្នុងវិស័យស្រាវជ្រាវ?
2. តើបរិយាកាសបច្ចុប្បន្នផ្តល់ការគាំទ្រយ៉ាងដូចម្តេចខ្លះដល់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ?
3. តើយើងអាចលើកកម្ពស់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវដោយរបៀបណា?

## វិធីសាស្ត្រ

របាយការណ៍នេះផ្អែកលើការសិក្សាដែលប្រើប្រាស់ការសម្ភាសបែបស៊ីជម្រៅ និងការស្ទង់មតិតាមប្រព័ន្ធអនឡាញ ដើម្បីប្រមូលទិន្នន័យពីអ្នកចូលរួមក្នុងការស្រាវជ្រាវ។ អ្នកចូលរួមចំនួន ១៦ នាក់ (ស្រី ៦ នាក់) ដែលបានចូលរួមក្នុងបទសម្ភាស។ អ្នកចូលរួមផ្តល់បទសម្ភាសរួមមាន និស្សិតសាកលវិទ្យាល័យ សាស្ត្រាចារ្យ ថ្នាក់ដឹកនាំសាកលវិទ្យាល័យ មន្ត្រីរាជការ បុគ្គលិកឬថ្នាក់ដឹកនាំអង្គការក្រៅរដ្ឋាភិបាល (NGOs) និងស្ថាប័នវិភាគ និងស្រាវជ្រាវ។ អ្នកចូលរួមការស្ទង់មតិតាមប្រព័ន្ធអនឡាញរួមមាន យុវជន ឬក្មេងជំទង់ ដែលមានចំនួន ៤៥៦នាក់ អាយុពីចាប់ពី ១៨ ដល់ ៣៥ ឆ្នាំ ដែលក្នុងចំណោមនោះ ៥២,២%ជាស្ត្រី ប្រហែល៧០%ជានិស្សិតសាកលវិទ្យាល័យ និងបីភាគបួនកំពុងសិក្សា ឬបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញា។ របាយការណ៍នេះក៏ទទួលបានអត្ថប្រយោជន៍ពីសិក្ខាសាលាពិគ្រោះយោបល់ ដែលបានធ្វើឡើងដើម្បីប្រមូលធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ដូចជា មន្ត្រីរដ្ឋាភិបាល អ្នកស្រាវជ្រាវ បុគ្គលិក/ថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យ ស្ថាប័នវិភាគ និងស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញយុវជនផងដែរ។ របកគំហើញនានាមានដូចខាងក្រោម៖

## គំហើញពីបទសម្ភាស

### *បញ្ហាប្រឈមចំពោះការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ*

ទិន្នន័យពីបទសម្ភាសបានបង្ហាញបញ្ហាប្រឈមចម្បងៗចំនួនបី ដែលប៉ះពាល់ដល់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ។ បញ្ហាប្រឈមទាំងនេះ រួមមាន៖ ១) ចំណេះដឹងអំពីការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងជំនាញភាសាអង់គ្លេសនូវមានកម្រិត ២) បរិយាកាស គាំទ្រដល់ការស្រាវជ្រាវ មិនសូវអំណោយផល ៣) បញ្ហាប្រឈមផ្ទាល់ខ្លួន និងវិជ្ជាជីវៈដទៃទៀត។ បញ្ហាប្រឈមទាំងនេះត្រូវបានបង្ហាញនៅក្នុងតារាងទី១។

**តារាងទី១**. បញ្ហាប្រឈមចំពោះការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យចំណេះដឹង

| | |
|---|---|
| 1. | ចំណេះដឹងអំពីការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងជំនាញភាសាអង់គ្លេសនូវមានកម្រិត<br>*(ឧ. កង្វះខាតការបណ្តុះបណ្តាល/សារតានៃការស្រាវជ្រាវជាមុន ចំណេះដឹងអំពីការស្រាវជ្រាវនៅមានកម្រិត ការផ្តោតលើការស្រាវជ្រាវនៅមានកម្រិត។ល។)* |
| 2. | កង្វះខាតបរិយាកាសដែលគាំទ្រដល់ការស្រាវជ្រាវ<br>*(ឧ. ឱកាសកសាងសមត្ថភាពស្រាវជ្រាវនៅមានកម្រិត បរិយាកាសមិនអំណោយផលដល់ការស្រាវជ្រាវ ការចូលប្រើប្រាស់ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំនៅមានកម្រិត។ល។)* |
| 3. | បញ្ហាប្រឈមផ្ទាល់ខ្លួន និងវិជ្ជាជីវៈដទៃទៀត<br>*(ឧ. ឧបសគ្គពេលវេលា ឧបសគ្គហិរញ្ញវត្ថុ ឧបសគ្គផ្នែកឥរិយាបថ/ផ្នត់គំនិតអវិជ្ជមានចំពោះការស្រាវជ្រាវ។ល។)* |

### *ឱកាសសម្រាប់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ*

បទសម្ភាសក៏បានគូសបញ្ជាក់អំពីឱកាសមួយចំនួន សម្រាប់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវផងដែរ។ ឱកាសទាំងនេះអាចត្រូវបានបែងចែកជាបួនប្រភេទ៖ ១) កម្មវិធី/គំនិតផ្តួចផ្តើមថ្មីៗដែលគាំទ្រការស្រាវជ្រាវ ២) វេទិកាថ្មីៗសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ ៣) ការផ្តោតលើការស្រាវជ្រាវ និងការបោះពុម្ពផ្សាយកាន់តែខ្លាំង និង ៤) ឱកាសដទៃទៀត។ ឱកាសទាំងនេះត្រូវបានសង្ខេបនៅក្នុងតារាងទី២។

**តារាងទី២**. ឱកាសសម្រាប់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ

| | |
|---|---|
| 1. | កម្មវិធី/គំនិតផ្តួចផ្តើមថ្មីៗដែលគាំទ្រការស្រាវជ្រាវ<br>*(ឧ. កម្មវិធីអ្នកស្រាវជ្រាវវ័យក្មេង ឱកាសទទួលបានការបណ្តុះបណ្តាល/ការណែនាំអំពីការស្រាវជ្រាវ កម្មវិធីកម្មសិក្សាស្តីពីស្រាវជ្រាវ។ល។)* |
| 2. | វេទិកាថ្មីៗសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ<br>*(ឧ. វេទិកាស្រាវជ្រាវថ្នាក់ជាតិ ទិន្នានុប្បវត្តិការស្រាវជ្រាវអំពីការអប់រំនៅកម្ពុជា ទិន្នានុប្បវត្តិ STEM កម្ពុជា និងការស្រាវជ្រាវអំពីការអប់រំ បណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ ។ល។)* |
| 3. | ការផ្តោតលើការស្រាវជ្រាវ និងការបោះពុម្ពផ្សាយកាន់តែខ្លាំង<br>*(ឧ. ការណែនាំអំពីចក្ខុវិស័យរបស់ស្ថាប័នដើម្បីលើកកម្ពស់ការស្រាវជ្រាវ ការណែនាំអំពីតម្រូវការនៃការស្រាវជ្រាវសម្រាប់និស្សិត។ល។)* |

| |
|---|
| 4. ឱកាសដទៃទៀត<br>*(ឧ. មានសាស្ត្រាចារ្យ និងគ្រូឧទ្ទេសកាន់តែច្រើន ដែលមានលក្ខណៈសម្បត្តិកាន់តែល្អប្រសើរ មកពីក្រៅប្រទេស ការគាំទ្រការស្រាវជ្រាវពីដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារផ្តល់ជំនួយ។ល។)* |

### *អនុសាសន៍ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ*

អ្នកចូលរួមត្រូវបានស្នើឱ្យផ្តល់អនុសាសន៍ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ។ ពួកគេបានផ្តល់យោបល់ជាច្រើន ដែលអាចបែងចែកជាបួនប្រភេទ៖ ១) ផ្តល់ការគាំទ្រការស្រាវជ្រាវ ២) ផ្តល់ឱកាសដល់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ ៣) បង្កើតបរិយាកាសដែលគាំទ្រដល់ការស្រាវជ្រាវ និង ៤) ផ្តោតលើការស្រាវជ្រាវ និងការបោះពុម្ពផ្សាយកាន់តែខ្លាំង។ អនុសាសន៍ទាំងនេះត្រូវបានបង្ហាញនៅក្នុងតារាងទី៣។

**តារាងទី៣.** អនុសាសន៍ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ

| |
|---|
| 1. ផ្តល់ការគាំទ្រការស្រាវជ្រាវ<br>*(ឧ. ការបែងចែកធនធាន/មូលនិធិ គ្រឿងលើកទឹកចិត្តសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ កម្មវិធីកសាងសមត្ថភាពស្រាវជ្រាវ ការគាំទ្រ/ការណែនាំសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ ។ល។)* |
| 2. ផ្តល់ឱកាសដល់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ<br>*(ឧ. កម្មវិធីកម្មសិក្សា/អាហារូបករណ៍ សិក្ខាសាលាស្តីពីការស្រាវជ្រាវ/សិក្ខាសាលា/សន្និសីទ/បទបង្ហាញ សកម្មភាពស្រាវជ្រាវ និងបោះពុម្ពផ្សាយ។ល។)* |
| 3. បង្កើតបរិយាកាសដែលគាំទ្រដល់ការស្រាវជ្រាវ<br>*(ឧ. បណ្តាញគាំទ្រការស្រាវជ្រាវ វេទិកាសម្រាប់ការបោះពុម្ពផ្សាយការស្រាវជ្រាវ កិច្ចសហការពីភាគីពាក់ព័ន្ធ/ស្ថាប័ន ការលើកកម្ពស់សេរីភាពក្នុងការសិក្សា។ល។)* |
| 4. ផ្តោតលើការស្រាវជ្រាវ និងការបោះពុម្ពផ្សាយកាន់តែខ្លាំង<br>*(ឧ. ការបង្កើតគោលនយោបាយស្រាវជ្រាវនៅតាមស្ថាប័ន លក្ខខណ្ឌតម្រូវនៃការស្រាវជ្រាវនៅក្នុងសាលារៀន កំណែទម្រង់កម្មវិធីសិក្សា និងការវាយតម្លៃ ការកែលម្អការចុះឈ្មោះចូលរៀន និងការគ្រប់គ្រងថ្នាក់ឧត្តមសិក្សា ការកែលម្អការអនុវត្តគោលនយោបាយ។ល។)* |

## គំហើញពីការស្ទង់មតិ

### *បទពិសោធន៍ការស្រាវជ្រាវរបស់យុវជនកម្ពុជា*







**រូបភាពទី១.** បទពិសោធន៍ស្រាវជ្រាវរបស់យុវជនកម្ពុជា

នៅពេលសួរថាតើពួកគេធ្លាប់ធ្វើការស្រាវជ្រាវដែរឬទេ ប្រហែល ៨៣% នៃអ្នកចូលរួមទាំង ៤៥៦ នាក់ បានអះអាងថា ពួកគេធ្លាប់ធ្វើការស្រាវជ្រាវ នៅខណៈពេលដែល ១៦,៩% ឆ្លើយថា ពួកគេមិនធ្លាប់ធ្វើការស្រាវជ្រាវនោះទេ។

នៅពេលសួរបន្ថែមទៀតថា តើពួកគេធ្លាប់ធ្វើការស្រាវជ្រាវប្រភេទណាខ្លះ អ្នកចូលរួមស្ទើរតែពាក់កណ្តាលបាននិយាយថា ពួកគេបានធ្វើវិធីស្រាវជ្រាវចម្រុះ។ ប្រហែល ២៤% បានអះអាងថាធ្លាប់ធ្វើការស្រាវជ្រាវដោយផ្អែកលើទិន្នន័យបន្ទាប់បន្សំ នៅខណៈពេលដែលប្រហែល ១២% បានរាយការណ៍ថា ធ្លាប់ធ្វើការស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ។ តិចជាង ៣% បានចូលរួមក្នុងការស្រាវជ្រាវប្រតិបត្តិ (សូមមើលរូបភាពទី១) ។

### *បញ្ហាប្រឈមសំខាន់ៗបំផុតចំពោះការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ*




**រូបភាពទី២.** បញ្ហាប្រឈមសំខាន់បំផុតទាំង ១០ ចំពោះការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ

អ្នកចូលរួមត្រូវបានផ្តល់ជូននូវបញ្ជីបញ្ហាប្រឈមជាសក្តានុពលចំនួន ២៤ ចំពោះការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ និងត្រូវបានស្នើសុំឱ្យជ្រើសរើសបញ្ហាប្រឈមសំខាន់បំផុតរបស់ពួកគេចំនួន ១០។ លទ្ធផលត្រូវបានបង្ហាញនៅក្នុងរូបភាពទី២ ខាងលើ។ ក្នុងចំណោមបញ្ហាប្រឈមទាំងនេះ បញ្ហាប្រឈមចំនួនបីត្រូវបានជ្រើសរើសញឹកញាប់បំផុត រួមមាន ១) កង្វះខាតការបណ្តុះបណ្តាលអំពីការស្រាវជ្រាវជាមុន ២) កង្វះខាតការអនុវត្តការស្រាវជ្រាវជាក់ស្តែង និង ៣) កង្វះខាតឱកាសទទួលបានបណ្តុះបណ្តាលអំពីការស្រាវជ្រាវ។

## *ឱកាសសម្រាប់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ*









**រូបភាពទី៣.** ការយល់ដឹងរបស់អ្នកចូលរួមអំពីឱកាសសម្រាប់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ

អ្នកចូលរួមត្រូវបានស្នើសុំឱ្យជ្រើសរើសកម្មវិធី សកម្មភាព និងឱកាសជាច្រើន ដែលទាក់ទងនឹងការស្រាវជ្រាវ។ លទ្ធផលត្រូវបានបង្ហាញនៅក្នុងរូបភាពទី៣ ខាងលើ។ សរុបមក អ្នកចូលរួមតិចជាងពាក់កណ្តាលបានដឹងអំពីកម្មវិធី សកម្មភាព និងឱកាសជាច្រើនដែលទាក់ទងនឹងការស្រាវជ្រាវ។ អ្នកចូលរួមប្រហែល ៤៤% បានដឹងអំពីឱកាសទទួលបានការបណ្តុះបណ្តាល និងការណែនាំអំពីការស្រាវជ្រាវ ប្រហែល ៣៧% ដឹងពីសិក្ខាសាលាស្តីពីការស្រាវជ្រាវជាបន្តបន្ទាប់ និងគោលនយោបាយ/គម្រោងថ្នាក់ជាតិស្តីពីការស្រាវជ្រាវ និងប្រហែល ៥០% ដឹងអំពីការពិតដែលថា មានសាស្ត្រាចារ្យ និងគ្រូឧទ្ទេសកាន់តែច្រើន ដែលមានគុណសម្បត្តិមកពីក្រៅប្រទេស ព្រមទាំងមានចំណាប់អារម្មណ៍កាន់តែខ្លាំងចំពោះការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ។ លទ្ធផលទាំងនេះបានចង្អុលបង្ហាញថា ការយល់ដឹងរបស់យុវជនកម្ពុជាអំពីឱកាសផ្សេងៗទាក់ទងនឹងការស្រាវជ្រាវដែលមាននៅមានកម្រិត។

### *អនុសាសន៍ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ*

**តារាងទី៤.** អនុសាសន៍ដែលបានទទួលភាគរយរួមបញ្ចូលគ្នាខ្ពស់បំផុតនៃ "យល់ស្រប" និង "យល់ស្របយ៉ាងខ្លាំង"

| អនុសាសន៍ | កម្រិតនៃការយល់ស្រប (%) | | |
|---|---|---|---|
| | SD/D | N | A/SA |
| ១. ការបែងចែកធនធាន/មូលនិធិដើម្បីគាំទ្រការស្រាវជ្រាវ | ១៤,៦៩ | ១០,០៩ | ៧៥,២២ |
| ២. គ្រឿងលើកទឹកចិត្តសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ | ១៤,០៤ | ៦,៥៨ | ៧៩,៣៩ |
| ៣. កម្មវិធីកសាងសមត្ថភាពស្រាវជ្រាវ/ការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ (សម្រាប់បុគ្គលិកផ្នែកបង្រៀន) | ១៤,២៥ | ៦,៨០ | ៧៨,៩៥ |
| ៤. ការគាំទ្រ/ការណែនាំសម្រាប់សកម្មភាពនៃការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ | ១៤,៤៧ | ៨,៥៥ | ៧៦,៩៧ |
| ៥. ផ្តល់ឱកាសធ្វើការស្រាវជ្រាវ និងបោះពុម្ពផ្សាយ | ១៤,៦៩ | ៧,២៤ | ៧៨,០៧ |
| ៦. កម្មវិធីកម្មសិក្សា/អាហារូបករណ៍ស្តីពីការស្រាវជ្រាវ | ១៤,២៥ | ៨,៣៣ | ៧៧,៤១ |
| ៧. សិក្ខាសាលាស្តីពីការស្រាវជ្រាវ/សិក្ខាសាលា/សន្និសីទ/បទបង្ហាញ | ១៤,០៤ | ៩,៤៣ | ៧៦,៥៤ |
| ៨. កម្មវិធី/គំនិតផ្តួចផ្តើមនៃការស្រាវជ្រាវ | ១៣,៣៨ | ១០,៥៣ | ៧៦,១០ |
| ៩. សកម្មភាព/ឱកាសធ្វើការស្រាវជ្រាវកាន់តែច្រើនសម្រាប់យុវជនក្នុងការចូលរួមនៅក្នុងការស្រាវជ្រាវ | ១៣,៣៨ | ៨,៥៥ | ៧៨,០៧ |
| ១០. សកម្មភាពនៃការស្រាវជ្រាវ និងការបោះពុម្ពផ្សាយកាន់តែច្រើន ដើម្បីបង្កើនចំណាប់អារម្មណ៍លើការស្រាវជ្រាវ | ១៣,៨២ | ៩,២១ | ៧៦,៩៧ |
| ១១. បណ្តាញគាំទ្រការស្រាវជ្រាវនៅក្នុង និងនៅក្រៅសាកលវិទ្យាល័យ | ១៥,៣៥ | ៧,៨៩ | ៧៦,៧៥ |

| | | | |
|---|---|---|---|
| ១២. ការលើកកម្ពស់ទំនាក់ទំនងរវាងសិស្ស-គ្រូបង្រៀន | ១២,៩៤ | ១១,១៨ | ៧៥,៨៨ |
| ១៣. ភាពសកម្មរបស់យុវជន | ១២,៧២ | ១១,១៨ | ៧៦,១០ |

*សម្គាល់.* SD/D = មិនយល់ស្របយ៉ាងខ្លាំង/មិនយល់ស្រប N = អព្យាក្រឹត្យ និង A/SA = យល់ស្រប/យល់ស្របយ៉ាងខ្លាំង

អ្នកចូលរួមត្រូវបានផ្តល់ជូននូវបញ្ជីអនុសាសន៍ជាសក្តានុពលចំនួន ៣៤ សម្រាប់ការលើកកម្ពស់ការចូលរួមរបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវ។ ពួកគេត្រូវបានស្នើសុំឱ្យវាយតម្លៃអនុសាសន៍ទាំងនេះនៅលើមាត្រដ្ឋាន Likert ប្រាំចំណុច ដែលរួមមាន ១) មិនយល់ស្របយ៉ាងខ្លាំង ២) មិនយល់ស្រប ៣) អព្យាក្រឹត្យ ៤) យល់ស្រប និង ៥) យល់ស្របយ៉ាងខ្លាំង។ លទ្ធផលបានបង្ហាញថាអនុសាសន៍ចំនួន ១៣ បានទទួលភាគរយរួមបញ្ចូលគ្នាខ្ពស់បំផុត (៧៥% ឡើងទៅ) នៃ "យល់ស្រប" និង "យល់ស្របយ៉ាងខ្លាំង"។ អនុសាសន៍ទាំងនេះត្រូវបានបង្ហាញនៅក្នុងតារាងទី៤ ខាងលើ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សានេះបានគូសបញ្ជាក់អំពីបញ្ហាប្រឈម/ឧបសគ្គជាច្រើន ព្រមទាំងឱកាសថ្មីៗមួយចំនួនសម្រាប់យុវជនកម្ពុជាក្នុងការចូលរួមនៅក្នុងវិស័យស្រាវជ្រាវ ក្នុងនាមជាអ្នកប្រើប្រាស់ការស្រាវជ្រាវ អ្នកផលិតការស្រាវជ្រាវ និងអន្តរការីការស្រាវជ្រាវ។

ការសិក្សានេះអះអាងថា បរិយាកាសបច្ចុប្បន្នមិនសូវអំណោយផលដល់យុវជនកម្ពុជាក្នុងការចូលរួមយ៉ាងសកម្មនៅក្នុង វិស័យស្រាវជ្រាវនោះទេ។ ដូច្នេះ បញ្ហាប្រឈមទាំងនេះចាំបាច់ត្រូវតែដោះស្រាយ ដើម្បីធ្វើឲ្យយុវជនកម្ពុជាកាន់តែច្រើនចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពស្រាវជ្រាវ និងផលិតការស្រាវជ្រាវ ដើម្បីរួមចំណែកលើកស្ទួយវិស័យស្រាវជ្រាវនៅកម្ពុជា។ ស្របពេលជាមួយគ្នានេះ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពីភាគីពាក់ព័ន្ធ ជាពិសេសរដ្ឋាភិបាល និងស្ថាប័នអប់រំ ដើម្បីធានានិរន្តរភាពនៃឱកាសធ្វើការស្រាវជ្រាវដែលមានស្រាប់ និងឱកាសថ្មីៗ ដើម្បីឲ្យយុវជនកម្ពុជាកាន់តែច្រើនមានឱកាសច្រើនក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងវិស័យស្រាវជ្រាវ។

ការសិក្សានេះក៏បានកំណត់បណ្តុំអនុសាសន៍ដែលគួរពិចារណា ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការចូលរួមកាន់តែខ្លាំងក្លារបស់យុវជនកម្ពុជានៅក្នុងវិស័យស្រាវជ្រាវផងដែរ។ អនុសាសន៍ផ្សេងៗរួមមាន ការផ្តល់ការគាំទ្រការស្រាវជ្រាវ បង្កើនឱកាសស្រាវជ្រាវ និងការបោះពុម្ពផ្សាយឱ្យកាន់តែច្រើន បង្កើតបរិយាកាសអំណោយផលដល់ការស្រាវជ្រាវ និងសង្កត់ធ្ងន់លើសកម្មភាពស្រាវជ្រាវ និងបោះពុម្ពផ្សាយ។ ការសិក្សានេះផ្តល់អនុសាសន៍បន្ថែមចំនួនបួនដូចខាងក្រោម៖

### *ផ្តល់ឱកាសសម្រាប់ការកសាងសមត្ថភាពស្រាវជ្រាវ*

វាមានសារៈសំខាន់ក្នុងការធានាថា យុវជនកម្ពុជា ជាពិសេសនិស្សិតសាកលវិទ្យាល័យ មានចំណេះដឹង និងជំនាញចាំបាច់ ដើម្បីចូលរួមនៅក្នុងសកម្មភាពស្រាវជ្រាវ។ នេះអាចធ្វើឡើងនៅកម្រិតជាច្រើន រួមទាំង នៅថ្នាក់ជាតិ នៅកម្រិតសហគមន៍ និង កម្រិតស្ថាប័នផងដែរ។ ដូច្នេះ ឱកាសសម្រាប់ការកសាងសមត្ថភាពស្រាវជ្រាវបន្ថែមទៀត គួរតែអាចស្វែងរកបាន និងទទួលបានដោយយុវជន ដើម្បីធ្វើឱ្យពួកគេអាចអភិវឌ្ឍ

ចំណេះដឹង និងជំនាញស្រាវជ្រាវរបស់ពួកគេ ដើម្បីឱ្យពួកគេអាចបង្កើនសកម្មភាពនៃការចូលរួមនៅក្នុងការស្រាវជ្រាវរបស់ពួកគេ។

### *ផ្តល់ឱកាសសម្រាប់ការទទួលបានបទពិសោធន៍ជាក់ស្តែងអំពីការស្រាវជ្រាវ*

កម្មវិធីកម្មសិក្សាស្តីពីការស្រាវជ្រាវជាច្រើន គួរតែត្រូវបានផ្តល់ជូនដោយភាគីពាក់ព័ន្ធ ជាពិសេសស្ថាប័នអប់រំ វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុងកម្មវិធីដែលផ្តោតលើការស្រាវជ្រាវបែបនេះ យុវជនគួរតែត្រូវបានផ្តល់ជូននូវឱកាសធ្វើការស្រាវជ្រាវ និងអាចទទួលបានការគាំទ្រផ្ទាល់ខ្លួននៅក្នុងទម្រង់នៃការណែនាំ។ នេះគឺដើម្បីធ្វើឱ្យពួកគេមានបទពិសោធន៍ដោយផ្ទាល់នៅក្នុងការស្រាវជ្រាវ និងមានឱកាសអភិវឌ្ឍចំណេះដឹង និងជំនាញស្រាវជ្រាវរបស់ពួកគេ តាមរយៈការគាំទ្រ និងការណែនាំដោយផ្ទាល់។

### *ផ្តល់ការគាំទ្រដល់ការបោះពុម្ពផ្សាយ*

វាមានសារៈសំខាន់ក្នុងការផ្តល់ជូនយុវជននូវបទពិសោធន៍ធ្វើការស្រាវជ្រាវដោយផ្ទាល់ និងការសរសេរសម្រាប់បោះពុម្ពផ្សាយ។ ដើម្បីសម្រេចគោលដៅនេះ កម្មវិធីបណ្តុះបណ្តាល ឬការណែនាំ ដែលមានបំណងអភិវឌ្ឍជំនាញសរសេរ និងការបោះពុម្ពផ្សាយរបស់យុវជន គឺចាំបាច់ណាស់ ដើម្បីជួយពួកគេកសាងទំនុកចិត្ត និងពង្រឹងចំណាប់អារម្មណ៍របស់ពួកគេចំពោះការសរសេរ និងការបោះពុម្ពផ្សាយ។ ការគាំទ្រប្រភេទនេះអាចចាប់ផ្តើមបានតាមរយៈការផ្តោតលើការសរសេរអត្ថបទខ្លីៗ ឬអត្ថបទអត្ថាធិប្បាយ និងអាចវិវត្តទៅរកការចូលរួមនៅក្នុងទម្រង់នៃការសរសេរកម្រិតកាន់តែខ្ពស់ ដូចជា របាយការណ៍ស្រាវជ្រាវ និងអត្ថបទទិន្នានុប្បវត្តិជាដើម។

### *បង្កើតបណ្តាញគាំទ្រសម្រាប់យុវជន និងអ្នកស្រាវជ្រាវវ័យក្មេង*

វាមានសារៈសំខាន់ក្នុងការបង្កើតបណ្តាញគាំទ្រសម្រាប់យុវជន និងអ្នកស្រាវជ្រាវវ័យក្មេង។ បណ្តាញគាំទ្របែបនេះមានសារៈសំខាន់ណាស់ពីព្រោះវាជួយបង្កើតវេទិកាសម្រាប់ឲ្យយុវជន និងអ្នកស្រាវជ្រាវវ័យក្មេងជួប និងពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងចំណាប់អារម្មណ៍លើការស្រាវជ្រាវ និងគោលដៅនៃអាជីពរបស់ពួកគេ។ បណ្តាញគាំទ្រនេះ ប្រសិនបើត្រូវបានគាំទ្រ និងគ្រប់គ្រងបានល្អនោះ នឹងផ្តល់បរិយាកាសគាំទ្រដល់យុវជនក្នុងការអភិវឌ្ឍជំនាញ និងបំពេញបំណងប្រាថ្នារបស់ពួកគេក្នុងការចូលរួមចំណែកដល់វិស័យស្រាវជ្រាវរបស់ប្រទេសកម្ពុជា។ ដូច្នេះ វាមានសារៈសំខាន់ណាស់ដែលភាគីពាក់ព័ន្ធគួរតែធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ដើម្បីស្វែងរកមធ្យោបាយប្រកបដោយនវានុវត្តន៍ក្នុងការបង្កើតវេទិកាមួយ ដែលយុវជន និងអ្នកស្រាវជ្រាវវ័យក្មេងកម្ពុជាអាចស្វែងរកទម្រង់គាំទ្រខុសៗគ្នា នៅពេលចាំបាច់។ ការមានបណ្តាញគាំទ្រប្រកបដោយប្រសិទ្ធភាពនឹងរួមចំណែកដល់ការបង្កើតបរិយាកាស ដែលយុវជនមានភាពអង់អាចក្នុងការពង្រឹងតួនាទីរបស់ពួកគេក្នុងនាមជាអ្នកប្រើប្រាស់ អ្នកផលិត និងអន្តរការីស្រាវជ្រាវនៅក្នុងវិស័យស្រាវជ្រាវនៅកម្ពុជា។



កម្មវិធីពន្លកចំណេះ៖ទិន្នន័យនិងការពិភាក្សា
ដើម្បីការអភិវឌ្ឍនៅកម្ពុជាគឺជាកម្មវិធីមួយមានរយៈពេលបួនឆ្នាំ
ដែលផ្តួចផ្តើមឡើងដោយអង្គការមូលនិធិអាស៊ី
ក្នុងគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវ
ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ប្រកបដោយគុណភាព
ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ
និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា
ក្រោមការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។


## អង្គការមូលនិធិអាស៊ី

ផ្ទះលេខ៥៩ ផ្លូវ២៤២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ponlokchomnes@asiafoundation.org

+៨៥៥ ០២៣ ២១០ ៤៣១
https://policypulse.org/


Australian Aid

ពន្លក ចំណេះ

The Asia Foundation